**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសុខាភិបាល**

# សេចក្តីជូនព័ត៌មានរបស់ក្រសួងសុខាភិបាល
# ស្តីពី
# លទ្ធផលនៃកិច្ចប្រជុំលើកទី៣
# របស់ក្រុមការងារឆ្លើយតបការចម្លងវីរុសកូរ៉ូណាថ្មី (COVID-19)

ក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា សូមជម្រាបជូនសាធារណជនទាំងអស់ឲ្យបានជ្រាបថា ដើម្បីបន្តកិច្ចការសំខាន់ៗសម្រាប់ការឆ្លើយតបការចម្លងវីរុសកូរ៉ូណាថ្មី (COVID-19) ឲ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ និងការរៀនសូត្រដកបទពិសោធន៍នៃការគ្រប់គ្រង ការឆ្លើយតប ការស្រាវជ្រាវ ការពិនិត្យ និងការព្យាបាល ជាពិសេសកិច្ចការដែលបានធ្វើសម្រាប់ពិនិត្យសុខភាពអ្នកដំណើរតាមនាវាទេសចរណ៍ធំវេស្ទឺដាម (Holland America MS Westerdam) កិច្ចប្រជុំក្រុមការងារឆ្លើយតបការរាតត្បាតនៃវីរុសកូវីដ-១៩ បានប្រព្រឹត្តទៅនារសៀលថ្ងៃសុក្រ ១៣រោច ខែមាឃ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣ ត្រូវនឹងថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ ២០២០ នៅទីស្តីការក្រសួងសុខាភិបាល ក្រោមអធិបតីភាព **ឯកឧត្តមសាស្ត្រាចារ្យ ម៉ម ប៊ុនហេង** រដ្ឋមន្ត្រីក្រសួងសុខាភិបាល និងជាប្រធានក្រុមការងារ ដែលមានការអញ្ជើញចូលរួមពីសំណាក់ឯកឧត្តម លោកជំទាវ ជាអនុប្រធានក្រុមការងារ សមាជិក-សមាជិកា និងទីប្រឹក្សាបច្ចេកទេសនៃក្រុមការងារខាងលើ សរុបមានចំនួន៣៥នាក់។

ថ្វីត្បិតតែបច្ចុប្បន្ន មិនទាន់មានប្រជាជនកម្ពុជាណាម្នាក់ផ្ទុកនូវវីរុសនេះក៏ពិតមែន គោលបំណងនៃកិច្ចប្រជុំនេះ គឺដើម្បីពិនិត្យឡើងវិញនូវបទពិសោធន៍ យន្តការគ្រប់គ្រង និងពិភាក្សាផ្ទាំងរកនីតិវិធីប្រទាក់ក្រឡា សំដៅបន្តពង្រឹងយន្តការនៃការឆ្លើយតប ការស្រាវជ្រាវ និងការទប់ស្កាត់ការចម្លងវីរុសកូរ៉ូណាថ្មីនៅក្នុងព្រះរាជាណាចក្រកម្ពុជា ព្រមទាំងដាក់ចេញនូវវិធានការជាបន្តទៀត ក្នុងការបន្តវិធានការទប់ស្កាត់ការចម្លងវីរុសនេះនៅព្រះរាជាណាចក្រកម្ពុជា។

លទ្ធផលនៃអង្គប្រជុំក្រុមការងារឆ្លើយតបការរាតត្បាតនៃវីរុសកូវីដ-១៩ មានជាសង្ខេបដូចតទៅ៖

1. បន្តពង្រឹងទៅលើប្រព័ន្ធតាមដានជំងឺឆ្លងដែលមានស្រាប់ និងអង្កេតស្រាវជ្រាវករណីដែលសង្ស័យ ព្រមទាំងធ្វើបច្ចុប្បន្នភាពទិន្នន័យអេពីដេមីសាស្ត្រ ទាក់ទងនឹងការឆ្លងវីរុសកូរ៉ូណាថ្មី (COVID19) និងជំងឺឆ្លងផ្សេងៗទៀត បណ្តុះបណ្តាលអំពីការអង្កេតស្រាវជ្រាវ ការបង្ការការចម្លងដល់ក្រុមឆ្លើយតបបន្ទាន់ រាជធានី ខេត្ត។
2. បន្តពង្រឹងការប្រាស្រ័យទាក់ទងហានិភ័យ មានជាអាទិ៍ ការចេញសេចក្តីប្រកាសព័ត៌មានជម្រាបដល់សាធារណជនអំពីស្ថានភាព បច្ចុប្បន្នភាពនៃជំងឺ និងវិធានការបង្ការសុខភាពនានា បណ្តុះបណ្តាលអ្នកសារព័ត៌មាន បណ្តុះបណ្តាលដល់ក្រុមគ្រូពេទ្យ និងមន្ត្រីសុខាភិបាល អំពីវិធានការបង្ការការចម្លង និងពង្រឹងការប្រាស្រ័យទាក់ទងផ្ទៃក្នុង និងជាមួយអ្នកមកទទួលសេវា។
3. បណ្តុះបណ្តាលអប់រំសុខភាពផ្សព្វផ្សាយបន្ថែមជូនដល់ប្រជាពលរដ្ឋ សហគមន៍ សិស្សានុសិស្ស អាណាព្យាបាល និងជនងាយរងគ្រោះ អំពីវិធានការណ៍ការពារការចម្លងវីរុស និងចូលរួមរាយការណ៍ឲ្យទាន់ពេលវេលានូវករណីសង្ស័យ ចូលរួមចំណែកក្នុងការត្រៀមឆ្លើយតបក្នុងពេលមានការរាតត្បាតនៅក្នុងសហគមន៍ដែលអាចនឹងកើតឡើងជាយថាហេតុ។



ទីស្តីការក្រសួងសុខាភិបាល ផ្លូវលេខ ៨០ វិថីសម្តេច ប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥-២៣) ៨៨៥ ៩៧០ / ៨៨៤ ៩០៩

4. បន្តពង្រឹងលើសមត្ថភាពក្នុងការគ្រប់គ្រង ឆ្លើយតបទៅនឹងព័ត៌មានមិនពិត ព័ត៌មានក្លែងក្លាយ ដែលធ្វើឲ្យមានការយល់ច្រឡំមកលើកិច្ចខិតខំប្រឹងប្រែងរបស់ក្រសួងសុខាភិបាល ដែលមានចរិតបង្កឲ្យមានភាពចលាចលក្នុងសង្គម ធ្វើឲ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូរ និងកិត្តិយសរបស់ប្រទេសកម្ពុជា។

5. បន្តកិច្ចសហការយ៉ាងជិតស្និទ្ធ ជាមួយអង្គការសុខភាពពិភពលោក មជ្ឈមណ្ឌលប្រយុទ្ធនឹងជំងឺឆ្លងសហរដ្ឋអាមេរិក វិទ្យាស្ថានប៉ាស្ទ័រកម្ពុជា និងដៃគូសុខាភិបាលផ្សេងៗទៀត លើការងារទប់ស្កាត់ការចម្លងវីរុសកូវីដ-១៩ ព្រមទាំងបន្តផលិតឯកសារអប់រំសុខភាពពាក់ព័ន្ធ ដើម្បីចែកសារអប់រំសុខភាពទាំងនេះ ជូនដល់ថ្នាក់ក្រោមជាតិ បន្តផ្សព្វផ្សាយអប់រំ និងការពង្រឹងការងារចត្តាឡីស័កនៅតាមច្រកចេញចូលផងដែរ។

6. ក្រសួងស្នើសុំបទពិសោធន៍ និងនីតិវិធីក្នុងការព្យាបាលអ្នកជំងឺរលាកសួតដោយវីរុស (COVID-19) ដោយប្រើឱសថ ក្លរ៉ូគីនផូស្វាត (Chloroquine Chosphate) នៅសាធារណៈរដ្ឋប្រជាមានិតចិន ពីអង្គការសុខភាពពិភពលោក។

7. បន្តផ្គត់ផ្គង់ឱសថ សម្ភារៈ បរិក្ខារពេទ្យ និងសម្ភារៈការពារខ្លួន (PPE) ចាំបាច់ឲ្យបានសមស្របដល់មន្ទីរពេទ្យ។ ពិនិត្យមើលឡើងវិញនូវតំរូវការ និងបំពេញបន្ថែមនៅសម្ភារៈបរិក្ខារពេទ្យ និងឱសថព្រមទាំងភស្តុភារសម្រាប់ការត្រៀមឆ្លើយតបការចម្លងវីរុស (COVID-19) និងជំងឺឆ្លងផ្សេងៗទៀតនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

8. បន្តសម្របសម្រួលជាមួយ អង្គការសុខភាពពិភពលោក (WHO) មជ្ឈមណ្ឌលប្រយុទ្ធនឹងជំងឺឆ្លងសហរដ្ឋអាមេរិក (US-CDC) វិទ្យាស្ថានប៉ាស្ទ័រកម្ពុជា ស្ថានទូតពាក់ព័ន្ធ និងផ្នែកផ្សេងទៀត ក្នុងការស្វែងរកការឧបត្ថម្ភទាំងបច្ចេកទេសនិងថវិកា សម្រាប់សកម្មភាពការឆ្លើយតបខាងលើនេះ ឲ្យបានសមស្របនិងទាន់ពេលវេលា។

9. បន្តការសិក្សាស្រាវជ្រាវផ្នែកវិទ្យាសាស្ត្រវេជ្ជសាស្ត្រលើការពិនិត្យថែទាំ និងព្យាបាលជំងឺរលាកសួតដោយវីរុស (COVID-19) ដោយសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល ជាមួយសាធារណរដ្ឋប្រជាមានិតចិន និងដៃគូផ្សេងៗទៀត។

ក្រសួងសុខាភិបាល សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជាទីបំផុត ជូនដល់ថ្នាក់ដឹកនាំ មន្ត្រី-បុគ្គលិកសុខាភិបាល និងក្រុមគ្រូពេទ្យទាំងអស់នៅទូទាំងប្រទេស ព្រមទាំងស្ថាប័នពាក់ព័ន្ធ អាជ្ញាធររាជធានីភ្នំពេញ និងខេត្តព្រះសីហនុ ដែលបានខិតខំបំពេញភារកិច្ចបានល្អប្រសើរបំផុត ក្នុងការពិនិត្យសុខភាពក៏ដូចជាជួយសម្របសម្រួលដល់អ្នកដំណើរតាមនាវាវេស្ទើដាមទាំងអស់ ហើយក្រសួងនឹងបន្តកិច្ចសហការជាមួយអាជ្ញាធរ ស្ថាប័នពាក់ព័ន្ធជាតិ និងអន្តរជាតិ ជាបន្តទៀត នៅក្នុងបេសកកម្មទប់ស្កាត់ការចម្លងវីរុសកូវីដ-១៩ នេះ។ ក្រសួងសុខាភិបាល សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជាទីបំផុត ជូនចំពោះ **ឯកឧត្តម ឧត្តមសេនីយ៍ឯក ហ៊ីង ម៉ារ៉ែណត** អគ្គមេបញ្ជាការរង នៃកងយោធពលខេមរភូមិន្ទ មេបញ្ជាការកងទ័ពជើងគោក ដែលបានជួយគាំទ្រដល់ប្រតិបត្តិសុខាភិបាល ក្នុងការដឹកជញ្ជូនសំណាកអ្នកដំណើរ និងអ្នកបំរើការនាវាវេស្ទើដាម យកមកធ្វើវិភាគនៅវិទ្យាស្ថានប៉ាស្ទ័រកម្ពុជាតាមរយៈឧទ្ធម្ភាគចក្រ (Helicopter)។ ក្រសួងក៏សូមថ្លែងអំណរគុណចំពោះប្រទេសជប៉ុនដែលបានជួយឧបត្ថម្ភ PPE (Test kits) និងម៉ាស៊ីនស្កេនកំដៅ ដែលជាការរួមចំណែកនៅក្នុងកិច្ចការទប់ស្កាត់ការចម្លងវីរុស (COVID-19) នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ជាមួយគ្នានោះដែរ ក្រសួងសុខាភិបាល សូមថ្លែងអំណរគុណជាអនេកចំពោះ អង្គការសុខភាពពិភពលោក (WHO) មជ្ឈមណ្ឌលប្រយុទ្ធនឹងជំងឺឆ្លងសហរដ្ឋអាមេរិក (US-CDC) វិទ្យាស្ថានប៉ាស្ទ័រកម្ពុជា ស្ថានទូតពាក់ព័ន្ធ និងផ្នែកផ្សេងទៀត ដែលបានចូលរួមប្រតិបត្តិការសុខាភិបាលនាពេលកន្លងមកយ៉ាងសស្រាក់សស្រាំ។

**ឯកឧត្តមសាស្ត្រាចារ្យ ម៉ម ប៊ុនហេង** រដ្ឋមន្ត្រីក្រសួងសុខាភិបាល សូមធ្វើការណែនាំដល់ប្រជាពលរដ្ឋទាំងអស់ត្រូវអនុវត្តការប្រុងប្រយ័ត្ន និងធ្វើអនាម័យខ្ពស់ ដើម្បីកាត់បន្ថយការប៉ះពាល់និងការចម្លងជំងឺមួយចំនួន ដោយប្រកាន់អនាម័យស្អាត លាងដៃឲ្យបានញឹកញាប់ ជាមួយសាប៊ូនិងទឹកស្អាត ឬអាល់កុលហ្សែល ខ្ទប់មាត់និងច្រមុះនៅពេលក្អក និង

កណ្តាស់ ដោយប្រើម៉ាស់ ឬកន្សែងដៃ ឬក្រមា ឬក្រដាសជូតមាត់ រួចបោះចោលក្នុងធុងសំរាមឲ្យបានត្រឹមត្រូវ និងជៀសវាងទាក់ទង ជិតស្និទ្ធជាមួយអ្នកណាម្នាក់ដែលមានរោគសញ្ញាផ្លូវដង្ហើម ដូចជាក្អក និងកណ្តាស ជាដើម ។ បើលោកអ្នកគិតថាអាចមានប៉ះពាល់ជាមួយអ្នកមានជំងឺកូវីដដែលអះអាងបញ្ជាក់ដោយមន្ទីរពិសោធន៍ ឬ មកពីតំបន់ដែលជំងឺនេះកំពុងរាតត្បាត ហើយមានរោគសញ្ញាណាមួយក្នុងចំណោម គ្រុនក្តៅ ក្អក ឬពិបាកដកដង្ហើម ត្រូវស្វែងរកការពិគ្រោះយោបល់ឲ្យបានឆាប់រហ័ស នៅមន្ទីរពេទ្យ ឬមណ្ឌលសុខភាព និងផ្តល់ព័ត៌មានអំពីប្រវត្តិនៃការធ្វើដំណើររបស់អ្នកក្នុងអំឡុង១៤ថ្ងៃមុនដល់គ្រូពេទ្យដែលផ្តល់សេវាថែទាំពិគ្រោះជំងឺ។

ក្រសួងសុខាភិបាល និងបន្តធ្វើការជូនដំណឹងដល់សាធារណជនអំពីការវិវត្តនៃបញ្ហាសុខភាព តាមទំព័រហ្វេសប៊ុកឈ្មោះ៖ ក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងឈ្មោះ នាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង គេហទំព័ររបស់នាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង www.cdcmoh.gov.kh ដែលគេហទំព័រ នេះមានសម្ភារអប់រំសុខភាព ដែលអាចទាញយកមកមើល និងប្រើប្រាស់។ សម្រាប់ព័ត៌មានបន្ថែម៖ សូមទាក់ទងលេខទូរស័ព្ទទាន់ហេតុការណ៍ក្រសួងសុខាភិបាល 115 ដោយឥតគិតថ្លៃ ឬទំនាក់ទំនង ០១២ ៨២៥ ៤២៤ ឬ ០១២ ៤៨៨ ៩៨១ ឬ ០១២ ៨៣៦ ៨៦៨។

ថ្ងៃសុក្រ ១៣រោច ខែមាឃ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២០



ទីស្តីការក្រសួងសុខាភិបាល ផ្លូវលេខ ៨០ វិថីសម្តេចប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥-២៣) ៨៨៥ ៩៧០ / ៨៨៤ ៩០៩